ក្រុមប្រឹក្សាអាជ្ញាកណ្តាល
មជ្ឈមណ្ឌលភ្នំពេញ, អាគារ (A) , វិថី
សុធារស, សង្កាត់ទន្លេបាសាក់, ខណ្ឌចំការមន
ទូរស័ព្ទ/ទូរសារ : (៨៥៥-២៣)២២០ ៧៩៣

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**លេខ និងឈ្មោះសំណុំរឿង : ៦៣/០៥ - ក្រុមហ៊ុន ហារ តា**
**កាលបរិច្ឆេទនៃសេចក្តីបង្គាប់ : ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០០៥**

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា៣១៣នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

- អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក : កញ្ញា **យូ សួនទី**
- អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត : លោក **ទូន ស៊ីផាន់**
- ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ : លោក **ប៉ែន ប៊ុនឈា**

## ភាគីនៃវិវាទ

**១- ភាគីនិយោជក**

**ឈ្មោះ :** ក្រុមហ៊ុន ហារ តា ផាកខេជីង អ៊ីនដាស់ស្ទ្រី (ខេមបូឌា) លីមីតធីត

**អាសយដ្ឋាន :** ផ្លូវ ជាតិលេខ ៤ ឃុំ កន្ទោក ស្រុក អង្គស្នួល ខេត្ត កណ្តាល

**ទូរស័ព្ទ :** (៨៥៥) ១២ ៩៨៨ ៤៥៧

**តំណាងភាគីនិយោជក :**

១- លោក សូ ភក្តី ជំនួយការរដ្ឋបាល

២- លោក លី ចាងសាំង ជំនួយការរដ្ឋបាល

**២- ភាគីកម្មករនិយោជិត**

**ឈ្មោះ :** សហព័ន្ធសហជីពឯករាជ្យកម្ពុជា

**អាសយដ្ឋាន :** ផ្ទះលេខ១៩អា ផ្លូវលេខ ៣៤៨ សង្កាត់បឹងកេងកង ៣ ខណ្ឌចំការមន រាជធានីភ្នំពេញ

**ទូរស័ព្ទ :** (៨៥៥) ២៣ ២១៣ ៣៥៦, (៨៥៥) ១២ ៨៨៤ ០៥៧

**តំណាងកម្មករនិយោជិត :**

| | |
|---|---|
| ១- លោកស្រី ទេព គឹមវណ្ណារី | អនុប្រធានសហពន្ធ័សហជីពឯករាជ្យកម្ពុជា |
| ២- លោកស្រី ហ៊ុល មុំ | អគ្គលេខាធិការសហពន្ធ័សហជីពឯករាជ្យកម្ពុជា |
| ៣- លោក វ៉ាន់ សោភា | ប្រធានសហជីពឯករាជ្យកម្មករកម្ពុជា |
| ៤- លោក ជា រត្ន័ | មន្ត្រីសហព័ន្ធសហជីពឯករាជ្យកម្ពុជា |

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១. ភាគីកម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនទទួលយកលោក **វ៉ាន់ សោភា** ដែលជាប្រធានគណៈកម្មាធិការសហជីពមូលដ្ឋានប្រចាំ **ក្រុមហ៊ុន ហារ តា** ចូលធ្វើការដូចធម្មតាវិញ ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាល ទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី ១២ ផ្នែកទី ២ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ ១៩៩៧ ។ ប្រកាសលេខ ០៩៩ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល ។ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាលដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ និង ប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ៥១៣ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០៥ (អាណត្តិទីបី) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី ១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាគ្រប់ចំណុចទាំងអស់ឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជា លេខ ០០១ ក.ប.វ/ក.ណ ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០០៥ បានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០០៥ ។

## សវនាការ និង សង្ខេបនីតិវិធីមុនពេលក្រុមប្រឹក្សាអាជ្ញាកណ្តាល

**ទីកន្លែងសវនាការ :** ក្រុមប្រឹក្សាអាជ្ញាកណ្តាល មជ្ឈមណ្ឌលភ្នំពេញ អគា "A" វិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ :** ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០០៥ វេលាម៉ោង ១៥:០០ នាទី រសៀល ។

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី : គ្មាន

**ឯកសារ វត្ថុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

ក- ឯកសារបានទទួលពីភាគីនិយោជក

១- លិខិតផ្ទេរសិទ្ធិរបស់ក្រុមហ៊ុន ជូនលោក លី ចាងស៊ាំង និងលោក សូ ភក្តី ចូលរួមដោះស្រាយវិវាទនៅក្រុមប្រឹក្សាអាជ្ញាកណ្តាល ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ ២០០៥

២- បទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន ហារ តា ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០០៥

៣- វិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ចុះថ្ងៃទី ២៧ ខែ មេសា ឆ្នាំ២០០៤

៤- វិញ្ញាបនប័ត្រចុះបញ្ជីអាករលើតម្លៃបន្ថែម ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០០៤

៥- កំណត់ហេតុស្តីពីការបញ្ឈប់ការងារលោក វ៉ាន់ សោភា ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៥

៦- លិខិតព្រមានលោក វ៉ាន់ សោភា ចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០០៥ និង ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៥

៧- ប័ណ្ណថតចំលងនៃការវាយបុងចេញ-ចូលរោងចក្រ របស់លោក វ៉ាន់ សោភា

៨- ឯកសារកត់ត្រារបស់សន្តិសុខរោងចក្រ ស្តីពីការមកធ្វើការយឺតរបស់លោក វ៉ាន់ សោភា ។

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិតៈ

១- លិខិតរបស់គណៈកម្មាធិការសហព័ន្ធសហជីពឯករាជ្យកម្ពុជា ជូនចំពោះ លោកនាយកក្រុមហ៊ុន ហារ តា ស្តីពីសមាសភាពអ្នកដឹកនាំសហជីពឯករាជ្យកម្មករកម្ពុជាប្រចាំក្រុមហ៊ុន ហារ តា លេខ ០៧២/២០០៥ ស.ស.ឯ.ក ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០៥

២- លិខិតរបស់គណៈកម្មាធិការសហព័ន្ធសហជីពឯករាជ្យកម្ពុជា ជូនចំពោះ លោកប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល លេខ ០៧៦/២០០៥ ស.ស.ឯ.ក ចុះថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០០៥ ស្តីពី ការប្តឹងនាយករោងចក្រ ហារ តា ដែលបានបញ្ឈប់លោក វ៉ាន់ សោភា ពីការងារ

៣- កំណត់ហេតុស្តីពីការផ្តល់ព័តិមាន របស់លោក វ៉ាន់ សោភា នៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្ត កណ្តាល ចុះថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០០៥

៤- ញត្តិគាំទ្រ របស់កម្មករ ៤៥ នាក់ ដែលគាំទ្រឱ្យក្រុមហ៊ុនទទួលលោក វ៉ាន់ សោភា ចូលធ្វើការវិញ ចុះថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០០៥

៥- លិខិតរបស់លោក វ៉ាន សោភា ប្រធានសហជីពឯករាជ្យកម្មករកម្ពុជា ជូនចំពោះលោក ប្រធានសហព័ន្ធសហជីពឯករាជ្យកម្ពុជា ចុះថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០០៥ ស្តីពី សំណើសុំជួយអន្តរាគមន៍ដើម្បីឱ្យបានចូលធ្វើការវិញ

៦- លិខិតបញ្ឈប់លោក វ៉ាន់ សោភា ពីការងារ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០០៥

៧- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួម ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០៥

៨- លក្ខន្តិកៈ សហជីពឯករាជ្យកម្មករកម្ពុជា ក្រុមហ៊ុន ហារ តា ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០៥

៩- បង្កាន់ដៃទទួលសំណុំរឿង របស់នាយកដ្ឋានវិវាទការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពីការសុំចុះបញ្ជិកាសហជីពឯករាជ្យកម្មករកម្ពុជាប្រចាំក្រុមហ៊ុន ហារ តា បានទទួលថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០០៥

១០-គណៈកម្មាធិការសហជីពឯករាជ្យកម្មករកម្ពុជាប្រចាំក្រុមហ៊ុន ហារ តា សូមគោរពជូនឯកឧត្តមរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពីសំណើសុំចុះបញ្ជិកាគណៈកម្មាធិការសហជីពឯករាជ្យកម្មករកម្ពុជាប្រចាំក្រុមហ៊ុន ហារ តា ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០០៥

១១-កំណត់ហេតុបោះឆ្នោតបង្កើតសហជីព ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០៥ ។

**គ- ឯកសារបានទទួលពីក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ**

១- លិខិតស្នើសុំឱ្យដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ហារ តា លេខ ១៧១៤ ក.ក.ប.វ របស់ឯកឧត្តម **ញ៉ែប ប៊ុនជិន** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចុះថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០០៥ ។

២-របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ហារ តា លេខ ០០១ ក.ប.វ/ក.ណ របស់លោក **ធុល នាង** ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០០៥ ។

៣-កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួម ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០៥ ។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីកម្មករនិយោជិត ចូលរួមសវនាការ លេខ ៣៤០ ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០០៥ ។

២- លិខិតអញ្ជើញភាគីនិយោជក ចូលរួមសវនាការ លេខ ៣៤១ ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ២០០៥។

## អង្គហេតុ

ក្រុមហ៊ុន ហារ តា ( Harta Packaging Industries Cambodia Ltd ) មានទីតាំងស្ថិតនៅ ឃុំកន្ទោក ស្រុកអង្គស្នួល ខេត្តកណ្តាល ជាក្រុមហ៊ុនផលិតកេសកាតុងសំរាប់ប្រើប្រាស់ក្នុងស្រុក ។ ក្រុមហ៊ុននេះមានជួល កម្មករនិយោជិតសរុបចំនួន ២២០ នាក់ ។ នៅថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៥ មន្ទីរការងារ និងបណ្តុះបណ្តាល វិជ្ជាជីវៈខេត្តកណ្តាល បានទទួលពាក្យបណ្តឹងរបស់សហព័ន្ធសហជីពឯករាជ្យកម្ពុជា ហើយបានធ្វើការផ្សះផ្សា នៅថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០៥ ប៉ុន្តែភាគីទាំងពីរមិនបានសះជានឹងគ្នាលើវិវាទនេះទេ ។

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់ភាគីកម្មករនិយោជិត និង ភាគីនិយោជក
- ក្រោយពីបានពិនិត្យឯកសារផ្សេងៗ ដែលបានដាក់ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល

## ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា :

ភាគីកម្មករនិយោជិតចង់អោយភាគីនិយោជកទទួលយកលោក វ៉ាន់ សោភា ឱ្យចូលធ្វើការវិញ ។ លោក វ៉ាន់ សោភា បានចូលធ្វើការក្នុងក្រុមហ៊ុន ហារ តា នេះនៅថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០០៤ ហើយមាន មុខងារជាអ្នកបញ្ចេញអីវ៉ាន់ ។

ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០០៥ លោក វ៉ាន់ សោភា មិនបានពាក់ស្បែកជើងឃ្លុបក្នុងពេលធ្វើការ ហើយ ក្រុមហ៊ុនបានព្រមានគាត់អំពីបញ្ហានេះ ។

ថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០០៥ វ៉ាន់ សោភា បានទៅធ្វើការយឺត ហើយក្រុមហ៊ុនបានផាកពិន័យគាត់ ជាទឹកប្រាក់ស្មើនឹងប្រាំរយ(៥០០)រៀល ។ នៅថ្ងៃនេះដែរ លោក វ៉ាន់ សោភា ត្រូវបានហៅទៅសួរនាំ ដើម្បីស្តី បន្ទោសអំពីការមិនពាក់ស្បែកជើងឃ្លុបក្នុងពេលធ្វើការ ប៉ុន្តែ វ៉ាន់ សោភា បានប្រាប់ក្រុមហ៊ុនថា ខ្លួនឈឺជើងមិន អាចពាក់ស្បែកជើងបាន ហើយក្រុមហ៊ុនបានពិនិត្យឃើញថា គាត់ឈឺជើងប្រាកដមែន រួចហើយក៏អនុញ្ញាតអោយ ធ្វើការដោយមិនពាក់ស្បែកជើងបាន។

ថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០០៥ លោក វ៉ាន់ សោភា បានមកធ្វើការងារយឺត ពេលនោះក្រុមហ៊ុនបាន អះអាងថា ខ្លួនបានពិន័យជាទឹកប្រាក់ចំនួន៧០០រៀល ប៉ុន្តែលោក វ៉ាន់ សោភា បានបដិសេធមិនឱ្យលុយទៅ ក្រុមហ៊ុនទេ ។

ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៥ វ៉ាន់ សោភា បានមកធ្វើការយឺតចំនួន១៩នាទី ភាគីក្រុមហ៊ុនមិនបាន ពិន័យគាត់ទេនៅពេលនោះ។

ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៥ វ៉ាន់ សោភា បានទៅវាយបុងចូលធ្វើការ៣៣នាទីក្រោយម៉ោង៧ព្រឹក ។

ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០០៥ ក្រុមហ៊ុនបានបញ្ឈប់ លោក រស់ សំអុល និង លោក ឡាំ សាលី ព្រមទាំងកម្មករប្រាំនាក់ផ្សេងទៀតពីការងារ ។

ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០៥ ក្រុមហ៊ុនបានហៅ វ៉ាន់ សោភា ទៅប្រាប់អោយប្តូរការងារទៅក្រុមប្លាស្ទិចវិញ ប៉ុន្តែ វ៉ាន់ សោភា មិនបានទៅធ្វើការងារថ្មីនេះទេ ហើយគាត់បានទៅផ្ទះបាត់ទៅ ដោយមិនបានប្រាប់ដំណឹងទៅក្រុមហ៊ុនទេ ។

ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០៥ កម្មករនិយោជិត មួយចំនួនបានទាំគ្នាធ្វើកូដកម្មទាមទារអោយក្រុមហ៊ុនទទួលយកលោក រស់ សំអុល និង លោក ឡាំ សាលី ព្រមទាំងកម្មករប្រាំនាក់ទៀត ចូលធ្វើការវិញ ។

ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៥ ក្រុមហ៊ុនបានព្រមានលោក វ៉ាន់ សោភា អំពីការទៅធ្វើការយឺត និងឈប់ឥតច្បាប់ ។ នៅថ្ងៃនេះដែរ ក្រុមហ៊ុនបានអនុញ្ញាតអោយលោក វ៉ាន់ សោភា ឈប់សំរាក ៧ថ្ងៃ ដោយគិតទាំងថ្ងៃទី ៣០ ខែ កក្កដា ផង ដែលត្រូវកាត់ចេញពីថ្ងៃឈប់សំរាកប្រចាំឆ្នាំ ដើម្បីគិតឡើងវិញអំពីការងាររបស់ខ្លួនថាតើគួរលាឈប់ពីការងារឬធ្វើការតទៅទៀត ។ ប៉ុន្តែលោក វ៉ាន់ សោភា បានឈប់តែពីរថ្ងៃកន្លះតែប៉ុណ្ណោះ គិតទាំងថ្ងៃទី៣០ ខែកក្កដា ផង ។

ថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៥ លោក វ៉ាន់ សោភា បានសំរេចចិត្តចូលធ្វើការវិញ ហើយសុខចិត្តទទួលយកការព្រមានពីក្រុមហ៊ុនដើម្បីបានធ្វើការជាធម្មតាវិញ ។

ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០៥ កម្មករនិយោជិតចំនួន ៣៥ នាក់ នៃក្រុមហ៊ុន ហារ តា បាននាំគ្នារៀបចំការបោះឆ្នោតបង្កើតសហជីពថ្មីមួយដែលមានឈ្មោះថា សហជីពឯករាជ្យកម្មករកម្ពុជា និងបោះឆ្នោតជ្រើសរើសសមាសភាពថ្នាក់ដឹកនាំសហជីពនេះ ។ នៅក្នុងការបោះឆ្នោតនោះ មានសមាសភាពឈរឈ្មោះចំនួន៧នាក់ និងបានជ្រើសរើសយកប្រធានសហជីពម្នាក់គឺ លោក វ៉ាន់ សោភា អនុប្រធានសហជីពម្នាក់គឺ លោក ប៉ា សុវណ្ណវិរិទ្ធ និងលេខាធិការសហជីពម្នាក់គឺ លោក រស់ សំអុល ។

ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០០៥ កម្មករនិយោជិត បានទៅដាក់ពាក្យសុំចុះបញ្ជិកាសហជីពឯករាជ្យកម្មករកម្ពុជានៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ប៉ុន្តែត្រូវបានក្រសួងតម្រូវអោយធ្វើឡើងវិញ ព្រោះមិនបានបំពេញបែបបទគ្រប់គ្រាន់ ។

ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០០៥ កម្មករនិយោជិតបានទៅសុំចុះបញ្ជិកាសហជីពរបស់ខ្លួនសារជាថ្មីម្តងទៀត ហើយទទួលបានបង្កាន់ដៃសុំចុះបញ្ជិកាពីក្រសួងមកវិញ ។

ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០៥ តំណាងសហជីពបានប្រគល់បង្កាន់ដៃសុំចុះបញ្ជិកាសហជីពថ្មីនេះទៅតំណាងនិយោជក ។

ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០៥ មានកូដកម្មមួយទៀតនៅមុខក្រុមហ៊ុន ហើយត្រូវបានដោះស្រាយនៅក្នុងក្រុមហ៊ុន ពីម៉ោងប្រមាណ៩ព្រឹកដល់ម៉ោងប្រមាណ១២:០០ថ្ងៃត្រង់ ដែលលោក វ៉ាន់ សោភា បានចូលរួមដែរ ។

ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៥ តំណាងកម្មករនិយោជិត បានប្រគល់កំណត់ហេតុនៃការបោះឆ្នោតបង្កើតសហជីព និងជ្រើសរើសតំណាង ទៅក្រុមហ៊ុនតាមរយៈសន្តិសុខរោងចក្រ ។ ក្រុមហ៊ុនបានទទួលនៅថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០០៥ ។

ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០០៥ ក្រុមហ៊ុនបានសំរេចចិត្តបញ្ឈប់លោក វ៉ាន់ សោភា ពីរការងារ ។

ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០០៥ ក្រុមហ៊ុនបានហៅលោក វ៉ាន់ សោភា ទៅប្រាប់អំពីការបញ្ឈប់ការងាររបស់គាត់ ហើយគាត់ត្រូវបានបញ្ឈប់ចាប់ពីថ្ងៃនោះមក ។

## ហេតុផលនៃសេចក្តីសម្រេច

លោក វ៉ាន់ សោភា បានចូលធ្វើការក្នុងក្រុមហ៊ុន ហារ តា នេះនៅថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០០៤ ហើយមានមុខងារជាអ្នកបញ្ចេញអីវ៉ាន់ ។

ភាគីកម្មករនិយោជិតទទួលស្គាល់ថា នៅថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០០៥ វ៉ាន់ សោភា មិនបានពាក់ស្បែកជើងឃ្លុបកំឡុងពេលធ្វើការទេ ប៉ុន្តែលោក វ៉ាន់ សោភា បានអះអាងថា គាត់ខ្លាចជាន់ប្រឡាក់ផលិតផលទាំងនោះទើបដោះស្បែកជើងចេញមុននឹងចូលទៅផ្នែកខាងក្នុង ហើយនិយោជកបានព្រមានគាត់អំពីបញ្ហានេះ ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការព្រមាននេះអាចចាត់ទុកថា ជាការព្រមានលើកទី១ ដែលក្រុមហ៊ុន តែងតែអនុវត្តតាមទំលាប់របស់ខ្លួន ដោយគ្មានវិធានដាក់វិន័យច្បាស់លាស់ទេ ដូចជាបទបញ្ជាផ្ទៃក្នុងជាដើម ។ នៅថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០០៥ លោក វ៉ាន់ សោភា ត្រូវបានហៅទៅសួរនាំដើម្បីស្តីបន្ទោសម្តងទៀតអំពីការមិនពាក់ស្បែកជើងឃ្លុបក្នុងពេលធ្វើការ ប៉ុន្តែលោក វ៉ាន់ សោភា បានប្រាប់ក្រុមហ៊ុនថា ខ្លួនឈឺជើងមិនអាចពាក់ស្បែកជើងបាន ហើយក្រុមហ៊ុនបានពិនិត្យឃើញថា គាត់ឈឺជើងប្រាកដមែន រួចហើយក៏អនុញ្ញាតអោយធ្វើការ ដោយមិនពាក់ស្បែកជើងបាន ។ នៅក្នុងសវនាការ ភាគីកម្មករនិយោជិតអះអាងថា នៅពេលដែលគាត់បង្ហាញនិយោជកនូវជើងឈឺរបស់គាត់ និយោជកបានឯកភាពអនុញ្ញាតអោយគាត់ដោះស្បែងជើងតទៅទៀត ។ ភាគីនិយោជកមិនបានជំទាស់នឹងការអះអាងនេះទេ ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា បន្ទាប់ពីនិយោជកបានអនុញ្ញាតអោយលោក វ៉ាន់ សោភា ធ្វើការដោយមិនបានពាក់ស្បែកជើងនោះ មានន័យថាគាត់គ្មានកំហុសទេ ។ ដូច្នេះ អំពើនេះមិនគួរចាត់ទុកថា ជាការព្រមានដល់ការធ្វើខុសអ្វីទេ ។

ភាគីទាំងពីរបានឯកភាពគ្នាក្នុងសវនាការថា នៅថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០០៥ លោក វ៉ាន់ សោភា បានទៅធ្វើការយឺត ហើយក្រុមហ៊ុនបានផាកពិន័យគាត់៥០០រៀល ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការផាក

ពិន័យនេះ គឺជាការដាក់វិន័យ ដល់កម្មករដែលបានធ្វើខុស ។ ដូច្នេះ ភាគីនិយោជក បានដាក់ទណ្ឌកម្មគាត់រួចទៅ ហើយ១មិនគួរដាក់ទណ្ឌកម្មម្តងទៀតនៅពេលក្រោយទេ (យោងតាមមាត្រា ២៨ នៃច្បាប់ការងារ) ។ ម្យ៉ាងទៀត នៅពេលនោះ ក្រុមហ៊ុនមិនទាន់មានបទបញ្ជាផ្ទៃក្នុងសំរាប់អនុវត្តលើកម្មករនៅឡើយទេ ។ ដូច្នេះ ការយឺតនេះ មិនមានលក្ខណៈច្បាស់លាស់ណាមួយ ដែលអាចចាត់ទុកថា ជាការដែលត្រូវទទួលការដាក់វិន័យបែបណាមួយនោះ ដែរ ។ នៅថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០០៥ លោក វ៉ាន់ សោភា បានមកធ្វើការយឺតទៀត ហើយក្រុមហ៊ុនបាន អះអាងថា ខ្លួនបានទាមទារអោយលោក វ៉ាន សោភា បង់ប្រាក់ផាកពិន័យ៧០០រៀល ចំណែកឯលោក វ៉ាន់ សោភា បានបដិសេធថា គាត់មិនបានផ្តល់អោយនូវប្រាក់ផាកពិន័យនេះទេ ។ នៅថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៥ លោក វ៉ាន់ សោភា មកធ្វើការយឺត ១៥ នាទី ហើយក្រុមហ៊ុនមិនបានផាកពិន័យគាត់ទេ ។ ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៥ លោក វ៉ាន់ សោភា បានទៅវាយបុងចូលធ្វើការ ៣៣នាទីក្រោយម៉ោង ៧:០០ព្រឹក ។ ភាគីទាំងពីរបាន ឯកភាពគ្នាថា បន្ទាប់ពីបានដឹងថា លោក វ៉ាន់ សោភា វាយបុងយឺត៣៣នាទី ក្រុមហ៊ុនបានហៅគាត់ទៅសាកសួរ នៅការិយាល័យរដ្ឋបាល ។ លោក វ៉ាន់ សោភា បានប្រាប់ក្រុមហ៊ុនថា ខ្លួនមកទាន់ពេល ប៉ុន្តែភ្លេចទៅវាយបុងចូល ហើយក្រុមហ៊ុនក៏អោយគាត់ទៅធ្វើការតទៅទៀត ។ ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០៥ ក្រុមហ៊ុនបានហៅលោក វ៉ាន់ សោភា ទៅប្រាប់អោយប្តូរការងារទៅក្រុមប្លស្ទិចវិញ ប៉ុន្តែលោក វ៉ាន់ សោភា មិនបានទៅធ្វើការថ្មីនេះទេ ហើយ គាត់បានទៅផ្ទះបាត់ទៅ ដោយមិនបានប្រាប់ដំណឹងទៅក្រុមហ៊ុនទេ ។ លោក វ៉ាន់ សោភា អះអាងថា នៅថ្ងៃនោះគាត់មិនស្រួលខ្លួន ហើយក៏ទៅផ្ទះបាត់ទៅ ដោយមិនបានប្រាប់ក្រុមហ៊ុនជាមុន ។ លុះដល់ស្អែកឡើងគឺ ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៥ លោក វ៉ាន់ សោភា បានទៅសុំច្បាប់ពីក្រុមហ៊ុន ហើយក្រុមហ៊ុនបានព្រមានលោក វ៉ាន់ សោភា អំពីការទៅធ្វើការយឺត និងឈប់ឥតច្បាប់ រួចបានប្រាប់អោយគាត់ឈប់សំរាក៧ថ្ងៃ ដោយដកចេញពី ថ្ងៃឈប់សំរាកប្រចាំឆ្នាំ ដើម្បីអោយគាត់គិតមើលថា តើចង់ធ្វើការតទៅទៀត ឬចង់លាឈប់ពីការងារ ។ លោក វ៉ាន់ សោភា ក៏បានឈប់ចំនួន២ថ្ងៃកន្លះ ហើយត្រឡប់ចូលធ្វើការវិញនៅថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៥ រួចប្រាប់ និយោជកថា ខ្លួនចូលធ្វើការវិញ ហើយសុខចិត្តទទួលថា ខ្លួនបានធ្វើខុសកន្លងមក ព្រោះឈប់ប៉ុណ្ណឹងថ្ងៃវាគ្រប់គ្រាន់ ណាស់ទៅហើយសំរាប់គាត់ ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការយល់ព្រមរបស់ភាគីនិយោជកថា សុខ ចិត្តអោយកាត់ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០៥ ជំនួសថ្ងៃឈប់សំរាកប្រចាំឆ្នាំនោះ និយោជកពិតជាយល់ព្រមថា ខ្លួនសុខចិត្តមិនដាក់ទណ្ឌកម្មណាមួយដល់លោក វ៉ាន់ សោភា ទេ ចំពោះការឈប់នោះ ។ ដូច្នេះ លោក វ៉ាន់ សោភា មិនមាន កំហុសទៀតទេ ចាប់ពីថ្ងៃដែលនិយោជកយល់ព្រមដោះដូរនឹងថ្ងៃឈប់សំរាកនោះមក ។

ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០៥ កម្មករនិយោជិតចំនួន៣៥នាក់ នៃក្រុមហ៊ុន ហារ តា បាននាំគ្នារៀបចំ ការបោះឆ្នោតបង្កើតសហជីពថ្មីមួយ ដែលមានឈ្មោះថា *"សហជីពឯករាជ្យកម្មករកម្ពុជា"* និងបោះឆ្នោតជ្រើសរើស សមាសសភាព និងសមាជិកគណៈកម្មាធិការសហជីពនេះ ។ នៅក្នុងការបោះឆ្នោតនោះ មានសមាសសភាពឈរ

ឈ្មោះចំនួន៧នាក់ និងបានជ្រើសរើសយកប្រធានសហជីពម្នាក់ អនុប្រធានសហជីពម្នាក់ និងលេខាធិការសហជីពម្នាក់ ។ យោងតាមកំណត់ហេតុរបស់ភាគីកម្មករនិយោជិត ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០៥ និង ការបញ្ជាក់របស់ភាគីកម្មករនិយោជិតក្នុងសវនាការ បានបង្ហាញថា នៅក្នុងការបោះឆ្នោតនោះ មានសមាសសភាពឈរឈ្មោះចំនួន០៧នាក់គឺ លោក រស់ សំអុល លោក វ៉ាន់ សោភា លោក ឡាំ សាលី លោក ប៉ា សុវណ្ណវិរិទ្ធ លោក មៀច សុជាតិ លោក គី ណាល់ និង លោក ផាន រស្មី ។ លទ្ធផលនៃការបោះឆ្នោតនេះមានដូចតទៅ លោក វ៉ាន់ សោភា ជាប់ឆ្នោតជាប្រធានសហជីព លោក ប៉ា សុវណ្ណវិរិទ្ធ ជាប់ឆ្នោតជាអនុប្រធានសហជីព និង លោក រស់ សំអុល ជាប់ឆ្នោតជាលេខាធិការសហជីព ។ បន្ទាប់ពីការបោះឆ្នោតរួចមក នៅថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០០៥ តំណាងសហជីពបានទៅដាក់ពាក្យសុំចុះបញ្ជិកាសហជីពឯករាជ្យកម្មករកម្ពុជា នៅក្នុងបញ្ជីសហជីពរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ប៉ុន្តែត្រូវបានក្រសួងតម្រូវអោយធ្វើឡើងវិញ ព្រោះនៅពេលនោះតំណាងសហជីពមិនបានបំពេញបែបបទគ្រប់គ្រាន់នៅឡើយ ។ នៅថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០០៥ តំណាងសហជីពបានទៅសុំចុះបញ្ជិកាសហជីពរបស់ខ្លួនសារជាថ្មីម្តងទៀត ហើយទទួលបានបង្កាន់ដៃសុំចុះបញ្ជិកាពីក្រសួងមកវិញ ។ នៅថ្ងៃទី ៣០ ខែសីហា ឆ្នាំ ២០០៥ តំណាងសហជីពបានប្រគល់បង្កាន់ដៃសុំចុះបញ្ជិកាសហជីពថ្មីនេះទៅតំណាងនិយោជក។ ភាគីនិយោជកបានទទួលស្គាល់ក្នុងសវនាការថា ខ្លួនបានទទួលបង្កាន់ដៃសុំចុះបញ្ជិកាសហជីពឯករាជ្យកម្មករកម្ពុជា នៅថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០៥ នោះ ។ ភាគីទាំងពីរបានបញ្ជាក់ដូចគ្នាថា នៅថ្ងៃនេះដែរ មានកូដកម្មមួយនៅមុខក្រុមហ៊ុន ដែលកម្មករនិយោជិតបាននាំគ្នាឈរ និងយកដុំថ្មទៅឃាំងផ្លូវមិនអោយចេញ-ចូលបាន ហើយត្រូវបានដោះស្រាយនៅក្នុងក្រុមហ៊ុនពីម៉ោងប្រមាណ៩ព្រឹកដល់ម៉ោងប្រមាណ ១២:០០ ថ្ងៃត្រង់ ដែលក្នុងនោះលោក វ៉ាន់ សោភា បានចូលរួមក្នុងការដោះស្រាយនោះដែរ ។ នៅក្នុងពេលដោះស្រាយនោះ ភាគីកម្មករនិយោជិត បានប្រាប់ដោយផ្ទាល់មាត់ទៅភាគីនិយោជកថា លោក វ៉ាន់ សោភា ត្រូវបានជាប់ឆ្នោតជាប្រធានសហជីពថ្មី ហើយទៅតំណាងអោយកម្មករនិយោជិត ។ ភាគីកម្មករនិយោជិតបានធ្វើលិខិតជូនទៅក្រុមហ៊ុន ដើម្បីជំរាបអំពីសមាសសភាពថ្នាក់ដឹកនាំសហជីពឯករាជ្យកម្មករកម្ពុជានៅថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០៥ ប៉ុន្តែរហូតដល់ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៥ ទើបតំណាងសហជីពបានប្រគល់កំណត់ហេតុ និងលទ្ធផលនៃការបោះឆ្នោតបង្កើតសហជីព និងជ្រើសរើសតំណាងសហជីពទៅឱ្យក្រុមហ៊ុន ។

ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០០៥ ក្រុមហ៊ុនបានសំរេចចិត្តបញ្ឈប់ វ៉ាន់ សោភា ពីរការងារ ដោយបញ្ជាក់មូលហេតុថា មិនស្តាប់ការណែនាំថ្នាក់លើ ។ នៅថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០០៥ ក្រុមហ៊ុនបានហៅ លោក វ៉ាន់ សោភា ទៅប្រាប់អំពីការបញ្ឈប់រូបគាត់ពីរការងារ ចាប់ពីថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០០៥ តរៀងមក ។ ភាគីនិយោជកមិនបានជូនដំណឹង និង/ឬ សុំការអនុញ្ញាតណាមួយពីអធិការការងារក្នុងការបញ្ឈប់លោក វ៉ាន់ សោភា ពីការងារនេះទេ ។

តាមមាត្រា ២៨២ ចែងថា *ប្រតិភូសហជីព ឬអតីតប្រតិភូសហជីព ដែលបានចាកចេញពីតំណែង ក្នុងរយៈពេលតិចជាងប្រាំមួយខែ បានទទួលសិទ្ធិប្រយោជន៍ដូចមានចែងក្នុងបញ្ញត្តិ នៃមាត្រា ២៩២ មាត្រា ២៩៣ និង មាត្រា ២៩៤ ទាក់ទងដល់ការបណ្តេញចេញ ការប្តូរតំណែង ឬការផ្លាស់ប្តូរមុខងាររបស់ប្រតិភូបុគ្គលិក* ។ មាត្រា ២៩៣ ត្រង់កថាខណ្ឌទី១ ចែងថា *"រាល់ការបញ្ឈប់ប្រតិភូបុគ្គលិក ឬរាល់ការបញ្ឈប់បេក្ខជនណាម្នាក់ពីការងាររបស់ខ្លួន អាចធ្វើទៅបាន លុះត្រាតែមានការយល់ព្រមពីអធិការការងារ ។ វិធានការការពារទាំងឡាយដូចគ្នានេះ ត្រូវអនុវត្តចំពោះអតីតប្រតិភូបុគ្គលិក ក្រោយពេលបញ្ចប់អាណត្តិរបស់ខ្លួនបីខែ និងក្នុងរយៈពេលបីខែ ចំពោះអតីតបេក្ខជនមិនជាប់ឆ្នោត ក្រោយការប្រកាសលទ្ធផលនៃការបោះឆ្នោត ។-----"* ។

យោងតាមប្រកាសលេខ ៣០៥ ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០០១ របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ត្រង់ប្រការ ៣ កថាខណ្ឌ៣ ចែងថា *កម្មករនិយោជិតទាំងអស់ដែល ជាបេក្ខជនសំរាប់ការបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំសហជីពទទួលបាននូវការ ការពារចំពោះការបញ្ឈប់ពីការងារដូចប្រតិភូបុគ្គលិកដែរ ។ ការការពារនេះមានរយៈពេល៤៥ថ្ងៃ មុនការបោះឆ្នោត ហើយត្រូវបានបញ្ចប់ក្នុងរយៈពេល៤៥ថ្ងៃ ក្រោយការបោះឆ្នោត ប្រសិនបើបេក្ខជនទាំងនេះមិនត្រូវបានជាប់ឆ្នោត ។ សហជីពត្រូវជូនដំណឹងទៅនិយោជក អំពីបេក្ខភាពនេះតាមគ្រប់មធ្យោបាយទាំងអស់ ដែលទុក ជាការបាន ។ ---* ។ ប្រការ៤ កថាខណ្ឌ១ ចែងថា *ចាប់តាំងពីពេលដាក់ពាក្យសុំចុះបញ្ជិកាសហជីព កម្មករនិយោជិតទាំងអស់ដែលជាស្ថាបនិក ឬកម្មករនិយោជិត ដែលស្ម័គ្រចិត្តចូលជាសមាជិកសហជីពនេះ ក្នុងពេលកំពុងស្នើសុំចុះបញ្ជិកា ត្រូវបានការពារដូចគ្នានឹងប្រតិភូបុគ្គលិកដែរ ។ ការការពារនេះមានរយៈពេលរហូតដល់ ៣០ ថ្ងៃ ក្រោយកាលបរិច្ឆេទនៃការចុះបញ្ជិកាសហជីព* ។ កថាខណ្ឌ២ចែងថា *ផុតរយៈពេលកំណត់ក្នុងកថាខណ្ឌខាងលើ ការការពារនេះត្រូវបានផ្តល់អោយអ្នកដឹកនាំសហជីពពាក់ក្នុងលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ២៨២ និង ២៩៣ នៃច្បាប់ស្តីពីការងារ* ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ទង្វើរបស់និយោជកដែលបានបញ្ឈប់លោក វ៉ាន់ សោភា ដែលត្រូវបានជាប់ឆ្នោតជាប្រធានសហជីពឯករាជ្យកម្មករកម្ពុជា និងដែលត្រូវបានការពារតាមផ្លូវច្បាប់ តាមមាត្រា និង ប្រការ ដូចបានរៀបរាប់ខាងដើមពីការងារនេះ ដោយពុំមានសុំ និង គ្មានការអនុញ្ញាតពីអធិការការងារនេះ បានបំពានលើមាត្រា ២៧៩ នៃច្បាប់ការងារឆ្នាំ ១៩៩៧ និង ប្រការ៣ និងប្រការ៤ នៃប្រកាសលេខ ៣០៥ របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០០១ ។ អាស្រ័យហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា លោក វ៉ាន់ សោភា ត្រូវតែបានអនុញ្ញាតអោយចូលធ្វើការនៅកន្លែងដើមវិញ ដោយរក្សាទុកនូវអតីតភាពការងារ និងទទួលអត្ថប្រយោជន៍ផ្សេងៗទៀតដដែល រួមទាំងអត្ថប្រយោជន៍ក្នុងរយៈពេលបញ្ឈប់កន្លងមកផង ។

យោងតាមការបង្ហាញភស្តុតាង អង្គហេតុ អង្គច្បាប់ និងហេតុផលដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ដូចតទៅ :

## សំរេច និង បង្គាប់

១- បង្គាប់អោយភាគីនិយោជកទទួលយកលោក វ៉ាន់ សោភា ចូលធ្វើការនៅកន្លែងដើមវិញ ចាប់ពីថ្ងៃដែលសេចក្តីបង្គាប់នេះចូលជាធរមាន ។

២- បង្គាប់អោយនិយោជកបើកប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗក្នុងកំឡុងពេលបញ្ឈប់ លោក វ៉ាន់ សោភា កន្លងមកពេញលេញ ដូចដែលគាត់បានទៅធ្វើការជាធម្មតា នៅថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០០៥ យ៉ាងយូរ ។

ប្រភេទនៃសេចក្តីបង្គាប់ : សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច

*សេចក្តីបង្គាប់នេះនឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ចំនួន០៨ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងរយៈពេលនេះទេ ។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក :

ឈ្មោះ : **យូ សួនឌី**

ហត្ថលេខា:-----------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត :

ឈ្មោះ : **ឡួន ស៊ីផាន់**

ហត្ថលេខា:-----------------------------

ប្រធានក្រុមអាជ្ញាកណ្តាល :

ឈ្មោះ : **ម៉ែន ម៉ុនឈា**

ហត្ថលេខា:----------------------------

**ឧបសម្ព័ន្ធនៃសេចក្តីបង្គាប់លេខ ៦៣/០៥ ក្រុមហ៊ុន ហារ តា**

# <u>យោបល់ជំទាស់</u>

យោងតាមប្រការ ៣៧ នៃប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខ្ញុំ **យូ សួនធី** សូមផ្តល់នូវយោបល់ជំទាស់ទៅនឹងចំណុចវិវាទ នៃសេចក្តីបង្គាប់ លេខ ៦៣/០៥ ក្រុមហ៊ុន ហារ តា ដូចតទៅ :

បទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន ហារ តា ផាកខេជីង អ៊ិនដាស់ស្ទ្រី ខេមបូឌា លីមីតធីត (ហារ តា) ត្រូវបានចុះទិដ្ឋាការជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៥ ។ យោងតាមមាត្រា ២៤ នៃច្បាប់ការងារ បទបញ្ជាផ្ទៃក្នុងត្រូវតែចុះទិដ្ឋាការដើម្បីមានប្រសិទ្ធិភាព ។ ទិដ្ឋាការនេះនឹងត្រូវទទួលបានក្នុងរយៈពេល ៦០ ថ្ងៃ ។

នៅក្នុងរយៈពេលមុនពេលចុះទិដ្ឋាការនេះ រហូតដល់ថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៥ ក្រុមហ៊ុន ហារ តា ពុំមានបទបញ្ជាផ្ទៃក្នុងដើម្បីគ្រប់គ្រងអាកប្បកិរិយាកម្មករនិយោជិតនៅពេលបំពេញការងារទេ ។ នៅពេលដែលគ្មានបទបញ្ជាផ្ទៃក្នុងនេះ និយោជកបានដាក់ពិន័យលើកម្មករនីមួយៗទៅតាមអង្គហេតុនៃកំហុសនីមួយៗ ។ ការដាក់ពិន័យមកលើលោក វ៉ាន់ សោភា គឺជាឧទាហរណ៏បញ្ជាក់ ។

មាត្រា ៧៨ នៃច្បាប់ការងារអនុញ្ញាតឱ្យនិយោជកបញ្ឈប់ការងារកម្មករនិយោជិតណា ដែលបានប្រព្រឹត្តកំហុសធ្ងន់ ។ មាត្រា ៨៣(ខ)(៣) កំណត់ថា កំហុសធ្ងន់ រួមមានការមិនគោរពតាមវិន័យការងារ សុវត្ថិភាព និងអនាម័យ ។ នៅពេលគ្មានបទបញ្ជាផ្ទៃក្នុង អ្វីដែលជាវិធានការងារសំរាប់រោងចក្រមួយគឺជាចំណុចដែលគួរតែត្រូវវិភាគ ដោយពិចារណាលើទំលាប់ និងការអនុវត្តក្នុងវិស័យឧស្សាហកម្មមួយ ។

និយោជកតែងតែរំពឹងថា កម្មករនិយោជិតទាំងអស់ត្រូវតែមកធ្វើការឱ្យបានទៀងទាត់ពេលវេលា ។ ការមកធ្វើការយឺតយ៉ាវដោយគ្មានមូលហេតុត្រឹមត្រូវ ត្រូវបានចាត់ទុកថា ជាការមិនគោរពបទបញ្ជាផ្ទៃក្នុង ។ ទោះបីជានិយោជកមិនមានបទបញ្ជាផ្ទៃក្នុងណាមួយសំរាប់កំណត់ឱ្យច្បាស់លាស់ អំពីការដាក់ទោសពិន័យមកលើការមកធ្វើការយឺតយ៉ាវ ក្នុងគោលបំណងឱ្យកម្មករនិយោជិតមកធ្វើការឱ្យបានទាន់ពេលវេលា ពុំមែនមានន័យថានិយោជកបានលះបង់សិទ្ធិក្នុងការដាក់ទោសពិន័យនេះឡើយ ។

ក្នុងខែកក្កដា និងខែសីហា ឆ្នាំ២០០៥ លោក វ៉ាន់ សោភា បានមកធ្វើការយឺតយ៉ាវជាច្រើនពេល ។ និយោជកបានដាក់ពិន័យជាច្រើនរូបភាព រួមមានទាំងការផាកពិន័យជាប្រាក់ ការផ្លាស់ប្តូរការងារ និងការបង្ខំឱ្យឈប់បំណាច់ឆ្នាំ ។ ការដាក់ទណ្ឌកម្មនេះ គឺដើម្បីឱ្យលោក វ៉ាន់ សោភា ឈប់បំពារបំពានលើបទបញ្ជាផ្ទៃក្នុង នៅពេលខាងមុខ ។ ប៉ុន្តែទោះបីជាត្រូវទទួលនូវការពិន័យជាច្រើនដងហើយ ក៏លោក វ៉ាន់ សោភា នៅតែបន្តមកធ្វើការយឺតទៀត គឺមកយឺតនៅថ្ងៃទី១២ ទី២០ និងទី២៩ ខែសីហា ឆ្នាំ២០០៥ ដោយគ្មានមូលហេតុ ។ ទោះបីជាមានការពិន័យពីភាគីនិយោជកយ៉ាងណាក៏ដោយលោក វ៉ាន់ សោភា នៅតែមកយឺតជាបន្តបន្ទាប់ ដែលទង្វើនេះអាចត្រូវបានចាត់ទុកថា ជាការប្រព្រឹត្តកំហុសធ្ងន់នៅក្នុងវិស័យឧស្សាហកម្មកាត់ដេរ ។ ការបន្តមកយឺតនេះ ក៏ជាមូលហេតុសំរាប់ឱ្យភាគីនិយោជកបញ្ឈប់ការងាររបស់លោក វ៉ាន់ សោភា ផងដែរ ។

តើនិយោជកត្រូវតែស្វែងរកការអនុញ្ញាតពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងការបញ្ឈប់លោក វ៉ាន់ សោភា ពីព្រោះលោក វ៉ាន់ សោភា គឺជាប្រធាន សហជីពឯករាជ្យកម្មករកម្ពុជាប្រចាំរោងចក្រ ហារ តា ដែរឬទេ ? នេះគឺជាសំណួរដែលត្រូវតែពិចារណាតាមអង្គហេតុជាក់ស្តែង និងច្បាប់ការងារ ។

សហជីពឯករាជ្យកម្មករកម្ពុជាប្រចាំរោងចក្រ ហារ តា បានរៀបចំសំណុំបែបបទសុំចុះបញ្ជិកានៅក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ នៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៥ យោងតាមបង្កាន់ដៃចុះបញ្ជិកា ចុះថ្ងៃ ខែ ឆ្នាំដដែល ។ មាត្រា ២៦៨ នៃច្បាប់ការងារ ដែលកំណត់ថា ប្រសិនបើក្រសួងទទួលបន្ទុកវិស័យការងារមិនបានឆ្លើយតបក្នុងរយៈពេលពីរខែបន្ទាប់ពីបានទទួលពាក្យសុំចុះបញ្ជិកា សហជីពត្រូវបានកំណត់ថា បានចុះបញ្ជិកាជាស្វ័យប្រវត្តិ ។ នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៥ ដែលជាថ្ងៃសវនាការ សហជីពឯករាជ្យកម្មករកម្ពុជាប្រចាំរោងចក្រ ហារ តា ពុំទាន់បានទទួលវិញ្ញាបនប័ត្រចុះបញ្ជិកាពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅឡើយទេ ។ យោងតាមមាត្រា ២៦៨ សហជីពនេះត្រូវបានកំណត់ថា បានចុះបញ្ជិកាជាស្វ័យប្រវត្តិ ។

មាត្រា ៤ នៃប្រកាសលេខ ៣០៥ ផ្តល់ការការពារចំពោះថ្នាក់ដឹកនាំសហជីព ។ ការការពារនេះមានប្រសិទ្ធិភាពចាប់ពីថ្ងៃដាក់ពាក្យសុំចុះបញ្ជិកាសហជីព ។ ការការពារនេះនៅតែត្រូវបានបន្ត បន្ទាប់ពីការចុះបញ្ជិកាត្រូវបានបញ្ចប់ ។ ដើម្បីទទួលបាននូវការការពារនេះ សហជីពត្រូវតែជូនដំណឹងទៅនិយោជកតាមគ្រប់មធ្យោបាយដែលទុកជាបានការ អំពីសមាសភាពថ្នាក់ដឹកនាំសហជីព ។ សហជីពត្រូវតែចំលងសេចក្តីជូនដំណឹងនេះជូនក្រសួងទទួលបន្ទុកវិស័យការងារ ។

តំណាងសហជីពឯករាជ្យកម្មករកម្ពុជាប្រចាំរោងចក្រ ហារ តា បានអះអាងថា នៅថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០៥ ដែលជាថ្ងៃទីមួយនៃកូដកម្មនៅរោងចក្រ ហារ តា សហជីពបានប្រគល់បង្កាន់ដៃចុះបញ្ជិកាសហជីព ឯករាជ្យកម្មករកម្ពុជាប្រចាំរោងចក្រ ហារ តា អោយសន្តិសុខរោងចក្រយកទៅឱ្យនិយោជក ។ បង្កាន់ដៃនេះ មានកត់ត្រាតែឈ្មោះសហជីព និងថ្ងៃ ខែ ឆ្នាំ ដែលសហជីពបានរៀបចំសំណុំបែបបទសុំចុះបញ្ជិកា ប៉ុន្តែមិនបាន កត់ត្រាពីសមាសភាពថ្នាក់ដឹកនាំសហជីពឡើយ ។

តំណាងសហជីពក៏បានអះអាងដែរថា នៅថ្ងៃទី៣១ ខែសីហា ឆ្នាំ ២០០៥ ដែលជាថ្ងៃទីពីរនៃការធ្វើកូដកម្ម សហជីពបានប្រគល់ឱ្យសន្តិសុខរោងចក្រយកលិខិតជូនដំណឹងអំពីសមាសភាពថ្នាក់ដឹកនាំសហជីព ដែលរួមមាន លោក វ៉ាន់ សោភា ជាប្រធានសហជីព និងកំណត់ហេតុបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំសហជីពជូននិយោជក ។ តំណាងនិយោជកបានអះអាងថា បានទទួលតែលិខិតជូនដំណឹងអំពីសមាសភាពថ្នាក់ដឹកនាំសហជីពប៉ុណ្ណោះនៅថ្ងៃ ទី១ ខែកញ្ញា ឆ្នាំ២០០៥ ដែលជាថ្ងៃនិយោជកបានសំរេចចិត្តបញ្ឈប់ការងារលោក វ៉ាន់ សោភា ។

ហេតុការណ៍នេះបានបង្ហាញថា សហជីពមិនបានប្រើប្រាស់មធ្យោបាយដែលទុកជាការបាន ដើម្បីជូនដំណឹង ទៅភាគីនិយោជកអំពីសមាសភាពថ្នាក់ដឹកនាំសហជីព ដើម្បីទទួលបាននូវការការពារសំរាប់ថ្នាក់ដឹកនាំសហជីព តាមច្បាប់ទេ ។ ម្យ៉ាងវិញទៀត សហជីពមិនបានចំលងជូនទៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អំពីការ ជូនដំណឹងនេះឡើយ ។ សហជីពគួរតែអនុវត្តតាមតំរូវការដែលមានចែងក្នុងមាត្រា ៤ នៃប្រកាស លេខ៣០៥ ដើម្បីទទួលបាននូវការការពារដែលច្បាប់បានកំណត់។

ដោយមិនបានទទួលពីសហជីពឯករាជ្យកម្មករកម្ពុជាប្រចាំរោងចក្រ ហារ តា នូវសេចក្តីជូនដំណឹងអំពី សមាសភាពថ្នាក់ដឹកនាំសហជីពតាមមធ្យោបាយដែលទុកជាការបាន ដើម្បីឱ្យនិយោជកបានដឹងអំពីសមាសភាពនេះ មុនពេលធ្វើសេចក្តីសំរេចចិត្តបញ្ឈប់ការងារលោក វ៉ាន់ សោភា និយោជកពុំចាំបាច់សុំការអនុញ្ញាតពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងការបញ្ឈប់ការងាររបស់លោក វ៉ាន់ សោភា ឡើយ ។ ដូច្នេះ ខ្ញុំសូមជំទាស់នឹង សេចក្តីបង្គាប់របស់មតិភាគច្រើន ។

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក**

**យូ សួនទី**